00785883

E127/6


## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens


**អនុស្សរណៈ:-អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការដាក់ចំណាត់ថ្នាក់ឡើងវិញទៅលើចម្លើយរបស់សាក្សីដែលអាចផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២**

កាលពីថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្គាល់ឃើញថាសាក្សីចំនួន ២៩ រូប ដែលអាចផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ បានផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរទៅសហចៅក្រមស៊ើបអង្កេត (ស.ច.ស) នៅក្នុងសំណុំរឿងផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក (*សូមមើល* ឯកសារ E127/4)។ អង្គជំនុំជម្រះបានសម្រេចថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យអង្គជំនុំជម្រះអាចពិនិត្យមើលឯកសារទាំងនេះ និងបានបង្គាប់សហព្រះរាជអាជ្ញាឱ្យដាក់ចម្លើយរបស់សាក្សីទាំង ២៩ រូប ដែលមានឈ្មោះនៅក្នុងឯកសារ E127.2 ក្នុងរយៈពេលមួយសប្តាហ៍ក្នុងប្រភេទជាឯកសារសម្ងាត់បំផុត គិតចាប់ពីថ្ងៃជូនដំណឹងដោយអង្គជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា ខ្លួននឹងសម្រេចថាតើឯកសារទាំងនេះគួរត្រូវបានដាក់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសម្ងាត់ដែរ ឬយ៉ាងណា នៅក្នុងពេលវេលាសមស្រប។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 02 / 2012
ម៉ោង (Time/Heure) : 13:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

ឯកសារដូចបានបញ្ជាក់ខាងលើ ត្រូវបានសហព្រះរាជអាជ្ញាដាក់ និងជូនដំណឹងកាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ (*សូមមើល* ឯកសារ E127/5.1.1 ដល់ E127/5.1.31)។ បន្ទាប់ពីបានពិនិត្យមើលចម្លើយទាំងអស់នេះឡើងវិញ អង្គជំនុំជម្រះសាលាដំបូងសម្រេចចាត់ថ្នាក់ចម្លើយនីមួយៗ ជាឯកសារសម្ងាត់វិញដើម្បីអនុញ្ញាតឲ្យភាគីអាចពិនិត្យមើលចម្លើយទាំងនេះបាន មុនពេលស្តាប់សក្ខីកម្មសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំង ២៩ រូបនេះនៅក្នុងសំណុំរឿង ០០២។